ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកម្មវិធីតស៊ូមតិរបស់យុវជនស្តីពីសិទ្ធិមនុស្ស របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស

តំណាងកម្ពុជាប្រចាំគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (អាយឆា) បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកម្មវិធីតស៊ូមតិរបស់យុវជនស្តីពីសិទ្ធិមនុស្សរបស់អាយឆា នាថ្ងៃទី១-២ ខែកញ្ញា ឆ្នាំ២០២៥ នៅសណ្ឋាគារ FairField by Marriot Phnom Penh និងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ រាជធានីភ្នំពេញ។

តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាតំណាងកម្ពុជាប្រចាំអាយឆា លោកជំទាវ **អ៊ុច និពន្ធ** តំណាងរងកម្ពុជាប្រចាំអាយឆា បានថ្លែងនូវកិច្ចស្វាគមន៍ប្រកបដោយភាពកក់ក្តៅទៅកាន់អង្គកម្មវិធី និងបានបញ្ជាក់ពីវត្ថុបំណងសំខាន់ៗនៃកម្មវិធីតស៊ូមតិរបស់យុវជនកម្រិតតំបន់អាស៊ាននេះ រួមមាន ដើម្បីបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិមនុស្ស បំណិននិយាយ ភាពជាអ្នកដឹកនាំ និងសាមគ្គីភាពក្នុងចំណោមយុវជនអាស៊ាន ជាដើម។ បន្ថែមលើនេះ លោកជំទាវ ក៏បានសង្កត់ធ្ងន់ពីតួនាទីដ៏សំខាន់របស់យុវជនក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស ព្រោះពួកគេនឹងក្លាយទៅជាអ្នកដឹកនាំសង្គមជាតិនាពេលអនាគត។ លោកជំទាវក៏បានថ្លែងអំណរគុណតំណាងអាយឆា ក៏ដូចជាលេខាធិការដ្ឋានអាស៊ាន ដែលតែងតែគាំទ្រដល់គំនិតផ្តួចផ្តើមនិងកម្មវិធីផ្សេងៗរបស់អាយឆាកម្ពុជា ជាពិសេស រាជរដ្ឋាភិបាលអូស្ត្រាលី តាមរយៈគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី(AHRC) ដែលបានគាំទ្រដល់ការរៀបចំកម្មវិធីតស៊ូមតិនាពេលនេះ។

លោកស្រី Bridget Collier អនុប្រធានស្ថានបេសកកម្ម តំណាងស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា បានបង្ហាញការសាទរចំពោះកម្មវិធីតស៊ូមតិនេះ និងបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលអូស្ត្រាលីចំពោះវិស័យសិទ្ធិមនុស្ស និងកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន រួមទាំងការគាំទ្រដល់ការអនុវត្តផែនការការងារប្រាំឆ្នាំរបស់អាយឆា។ លោកស្រីក៏បានបន្ថែមថា កម្មវិធីតស៊ូមតិនេះបានផ្តល់ឱកាសដ៏សំខាន់មួយដល់យុវជនអាស៊ានក្នុងការចែករំលែកមតិយោបល់កង្វល់ ព្រមទាំងអាទិភាពនៃវិស័យសិទ្ធិមនុស្ស។

ឯកឧត្តម Edmund Bon Tai Soon ប្រធាន និងជាតំណាងប្រទេសម៉ាឡេស៊ីប្រចាំអាយឆា បានថ្លែងអំណរគុណដល់អាយឆាកម្ពុជាដែលបានរៀបចំកម្មវិធីនេះឡើង និងថា អាយឆាកម្ពុជាឈានមុខគេក្នុងការយកចិត្តទុកដាក់លើយុវជន ព្រមទាំងបានរំលឹកពីប្រធានបទសិទ្ធិមនុស្សនៃកម្មវិធីតស៊ូមតិស្តីពីសិទ្ធិមនុស្សរបស់អាយឆាចំនួន ៦លើក នាពេលកន្លងៗ ក្នុងនោះ ឯកឧត្តមក៏បានអះអាងថា ការជជែកអំពីសិទ្ធិមនុស្សជាការលំបាកនិងមានលក្ខណៈរសើប ប៉ុន្តែអាយឆាបានខិតខំក្នុងការផ្តល់លម្ហប្រកបដោយសុវត្ថិភាពមួយ ដល់យុវជនក្នុងការជជែកពិភាក្សាជេញដោលលើប្រធានបទជាច្រើនក្នុងវិស័យសិទ្ធិមនុស្ស។

លោកស្រីសាស្ត្រាចារ្យ **Amy Maguire** សមាជិកក្រុមប្រឹក្សាស្រាវជ្រាវនៃ AHRC បានបង្ហាញពីតួនាទីរបស់ AHRC ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងវិស័យជាអាទិភាពដែលគណៈកម្មការនេះកំពុងផ្តោតលើ។ លោកស្រីសាស្ត្រាចារ្យក៏បានចែករំលែកអំពីការដោះស្រាយបណ្តឹង និងការគាំទ្ររបស់ AHRC ដល់ការស្រាវជ្រាវពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុនិងផលប៉ះពាល់លើសិទ្ធិមនុស្ស ព្រមទាំងការគាំទ្រដល់យុវជនទាំងក្នុងប្រទេសអូស្ត្រាលី និងក្នុងតំបន់អាស៊ាន។

អគារលេខ៣ ផ្លូវVI.13 ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Building #3, Street VI.13, Toul Kok Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh Tel: (855) 23 882 065

លោកជំទាវ Dato' Astanah Abdul Aziz អគ្គលេខាធិការរងអាស៊ាន បានសម្ដែងនូវការកោតសរសើរដល់អាយធា ដែលតែតែងយកចិត្តទុកដាក់ចំពោះយុវជន និងបានលើកឡើងថា កម្មវិធីតស៊ូមតិរបស់យុវជនស្ដីពីសិទ្ធិមនុស្ស គឺជាវេទិកាមួយដ៏សំខាន់សម្រាប់ការលើកកម្ពស់ការយល់ដឹង និងជំរុញកិច្ចសន្ទនាស្ដីពីសិទ្ធិមនុស្សក្នុងចំណោមយុវជនអាស៊ាន។ លោកជំទាវ ក៏បានបង្ហាញពីការប្ដេជ្ញាចិត្តរបស់អាស៊ានលើវិស័យសិទ្ធិមនុស្ស តាមរយៈការបង្កើតយន្តការស្ថាប័នផ្សេងៗ និងលិខិតុបករណ៍សិទ្ធិមនុស្សអាស៊ាន ជាដើម។ ទន្ទឹមនេះ លោកជំទាវក៏បានផ្ដល់នូវទស្សនទានមួយចំនួន ដើម្បីធានាដល់ការផ្ដល់សិទ្ធិអំណាចដល់យុវជន។

ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាតំណាងកម្ពុជាប្រចាំអាយធា បានអញ្ជើញជាអធិបតីក្នុងពិធីបិទកម្មវិធីតស៊ូមតិនេះ។ នៅក្នុងឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងថា កម្មវិធីតស៊ូមមតិនាពេលនេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស ហើយបំណងប្រាថ្នារបស់យុវជន បានរម្លឹកយើងពីសារៈសំខាន់នៃសន្តិភាពនិងសិទ្ធិមនុស្ស បើគ្មានសន្តិភាពយើងនឹងមិនអាចមានសូម្បីតែសិទ្ធិរស់រានមានជីវិត។ សន្តិភាព គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។ នៅកម្រិតអាស៊ាន ការរួបរួមនិងការប្រែក្លាយភាពខុសគ្នាឱ្យទៅជាមូលដ្ឋានសម្រាប់សន្តិភាព វិបុលភាព និងការគោរពសិទ្ធិមនុស្សនៅតែជាចំណុចខ្លាំងរបស់អាស៊ាន។ យុវជនបានបញ្ចេញសមត្ថភាព និងវោហារសាស្ត្រយ៉ាងប៉ិនប្រសប់ជាមួយឥរិយាបថគួរជាទីពេញចិត្ត តែយ៉ាងណាក្នុងនាមជាអ្នកដឹកនាំនាពេលអនាគតត្រូវតែខិតខំបន្ថែមទៀត ហើយអាស៊ានត្រូវរួមគ្នាប្រែក្លាយគោលការណ៍សិទ្ធិមនុស្សឱ្យទៅជាសកម្មភាពជាក់ស្ដែង។ ជាចុងក្រោយ ក្រៅពីសម្ដែងការសាទរដល់យុវជនជ័យលាភី និងយុវជនទាំងអស់ដែលបានចូលរួម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណជាថ្មីដល់ភាគីអូស្ត្រាលីដែលបានគាំទ្រដល់កម្មវិធីនេះ រួមទាំងភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកធ្វើឱ្យកម្មវិធីតស៊ូមតិរបស់យុវជនលើកទី៧ អាចដំណើរការទៅបានដោយជោគជ័យ។

សូមបញ្ជាក់ថា កម្មវិធីតស៊ូមតិនេះមានប្រធានបទចំនួនប្រាំពាក់ព័ន្ធនឹង ការពរពោះជំនួស សិទ្ធិស្ត្រី សិទ្ធិកុមារ ធម្មនុញ្ញអាស៊ាន និងសិទ្ធិទទួលបានការអប់រំ។ ជាលទ្ធផល ក្នុងចំណោមយុវជននៃប្រទេសសមាជិកអាស៊ានដែលបានចូលរួម យុវជនទទួលបាន**ជ័យលាភីនិយាយល្អបំផុត (Best Speakers)** ក្នុងចំណោមប្រធានបទទាំងប្រាំ រួមមាន **យុវជនកម្ពុជាចំនួន ៣រូប, ឥណ្ឌូណេស៊ី ១រូប, និងសិង្ហបុរី ១រូប**។ កម្មវិធីនេះ ទទួលបានការគាំទ្រផ្នែកថវិកាពីមូលនិធិអាយធា និងពីរាជរដ្ឋាភិបាលអូស្ត្រាលី និងដោយមានការចូលរួមពីតំណាងប្រទេសអាស៊ានប្រចាំអាយធា តំណាងប្រទេសអូស្ត្រាលី និង AHRC ប្រទេសទីម័រខាងកើត ស្ថាប័នតាមវិស័យរបស់អាស៊ាន លេខាធិការដ្ឋានអាស៊ាន ស្ថាប័នសិទ្ធិមនុស្សជាតិនៃប្រទេសសមាជិកអាស៊ាន យុវជនអាស៊ាន តំណាងស្ថានទូត និងក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបប្រមាណ ១២០នាក់។

កម្មវិធីតស៊ូមតិនេះ បានប្រព្រឹត្តទៅដោយរលូន និងពោរពេញដោយស្នាមញញឹម ភាពស្និទ្ធស្នាល និងទទួលបានការសាទរនិងកោតសរសើរពីសំណាក់អ្នកចូលរួមទាំងអស់ ជាមួយនឹងលទ្ធសម្រេចបានគួរជាទីមោទនៈ៕

ថ្ងៃអង្គារ ១០កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៥